**សាលាដំបូងខេត្តកំពង់ស្ពឺ**
សំណុំរឿងព្រហ្មទណ្ឌលេខ:១៥២
ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២៣
សាលក្រមព្រហ្មទណ្ឌលេខ:២៥៦ "ឈ"
ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២៤

# ក្នុងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងខេត្តកំពង់ស្ពឺ

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី១៩ ខែមករា ឆ្នាំ២០២៤ វេលាម៉ោង ០៩ និង ០០ នាទីព្រឹក នៅសាលសវនាការ(ក) ដោយមានសមាសភាព៖

## ក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ប្រធានក្រុមប្រឹក្សា
លោក [redacted] ចៅក្រមប្រឹក្សា
លោក [redacted] ចៅក្រមប្រឹក្សា

## តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារង

## ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជីសាលាដំបូង

## ដើម្បីជំនុំជម្រះលើជនជាប់ចោទ

១-ឈ្មោះ [redacted]ស្មី ហៅ **ម៉ោល** ភេទប្រុស អាយុ ១៥ឆ្នាំ (កើតថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០០៧) ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរនៅផ្ទះ ទីកន្លែងកំណើតភូមិ[redacted] ខេត្តកំពង់ស្ពឺ ទីលំនៅបច្ចុប្បន្ន ភូមិ[redacted] ខេត្តកំពង់ស្ពឺ ឪពុកឈ្មោះ [redacted] **រឿន** (ស) ម្តាយឈ្មោះ [redacted] **សុភាព** (រ) នៅលើរ ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន។

-ត្រូវបានឃុំខ្លួនជាបណ្តោះអាសន្ននៅពន្ធនាគារខេត្តកំពង់ស្ពឺ **តាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ:១២១៩** ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តកំពង់ស្ពឺ។

២-ឈ្មោះ [redacted] **វ៉េង** ហៅ ញ៉ាញ់ ភេទប្រុស អាយុ ១៨ឆ្នាំ (កើតថ្ងៃទី១៤ ខែមករា ឆ្នាំ២០០៥) ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរកម្មកររោងចក្រ ទីកន្លែងកំណើតភូ[redacted] ខេត្តកំពង់ស្ពឺ ទីលំនៅបច្ចុប្បន្នភូ[redacted] ខេត្តកំពង់ស្ពឺ ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] **ជ្រឹប** (រ) នៅលើរ ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន។

-ត្រូវបានឃុំខ្លួនជាបណ្តោះអាសន្ននៅពន្ធនាគារខេត្តកំពង់ស្ពឺ **តាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ:១២២០** ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តកំពង់ស្ពឺ។

៣-ឈ្មោះ [redacted] **ហ៊ង** ភេទប្រុស អាយុ ២៤ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរជាងម៉ូតូ ទីកន្លែងកំណើត [redacted] ខេត្តកំពង់ស្ពឺ ទីលំនៅបច្ចុប្បន្នភូមិ[redacted] ខេត្តកំពង់ស្ពឺ



Scanned with CamScanner

ឪពុកឈ្មោះ [redacted] ហ្សូរ (រ) ម្ដាយឈ្មោះ [redacted] សុវ៉ាន់ (រ) ប្រពន្ធឈ្មោះ [redacted] **ស្រីតួច** មានកូនចំនួន ០១នាក់ ប្រវត្តិនៃការផ្ដន្ទាទោសដោយតុលាការ គ្មាន។

-ត្រូវបានឃុំខ្លួនជាបណ្ដោះអាសន្ននៅពន្ធនាគារខេត្តកំពង់ស្ពឺ **តាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ:១២២១** ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តកំពង់ស្ពឺ។

ជាប់ចោទពីបទ: **កំហែងយកមានស្ថានទម្ងន់ទោសដោយប្រើប្រាស់អាវុធ** ប្រព្រឹត្តនៅចំណុចភូមិស្រែអូរ ឃុំពាំងល្វា ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២៣ តាមបញ្ញត្តិមាត្រា៣៦៣ និងមាត្រា៣៦៦ នៃក្រមព្រហ្មទណ្ឌ។

-ដោយមានលោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] **វស្នី** ហៅ **ង៉ោល** និងឈ្មោះ [redacted] **វ៉ែង** ហៅ ញ៉ាញ់។

-ដោយមានលោកមេធាវី [redacted] និងលោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] **ហ៉េង**។

## **<u>ដើមបណ្ដឹង</u>**

ឈ្មោះ [redacted] **សុផាន** ភេទប្រុស អាយុ ២២ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរកម្មករ ទីកន្លែងកំណើតភូមិសារ៉ាម ឃុំពាំងល្វា ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ ទីលំនៅបច្ចុប្បន្នភូមិសារាំ ឃុំពាំងល្វា ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ ឪពុកឈ្មោះ [redacted] សារ៉េត (រ) ម្ដាយឈ្មោះ [redacted] សាវ៉ុន (រ) នៅលីវ ប្រវត្តិនៃការផ្ដន្ទាទោសដោយតុលាការ គ្មាន។

## **<u>អង្គហេតុនៃរឿងមានដូចតទៅ</u>**

កាលពីថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២៣ វេលាម៉ោង ០១ និង ០០នាទីព្រឹក ស្ថិតនៅភូមិស្រែអូរ ឃុំពាំងល្វា ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ ជនជាប់ចោទមួយក្រុមមានឈ្មោះ [redacted] វ៉ែង ហៅ ញ៉ាញ់ ភេទប្រុស អាយុ ១៨ឆ្នាំ ឈ្មោះ [redacted] វស្នី ហៅ ង៉ោល ភេទប្រុស អាយុ ១៥ឆ្នាំ ឈ្មោះ [redacted] ហ៉េង ភេទប្រុស អាយុ ២៣ឆ្នាំ ឈ្មោះ [redacted] ភេទប្រុស អាយុប្រហែល ១៩ឆ្នាំ ឈ្មោះ ឆានី ភេទប្រុស អាយុ ១៧ឆ្នាំ ឈ្មោះ យ៉ាង ភេទប្រុស អាយុ ១៨ឆ្នាំ (មានកាន់កាំបិតផ្គាក់) ឈ្មោះ រ៉ុង ភេទប្រុស អាយុ ១៩ឆ្នាំ និងបក្ខពួកប្រហែល ០៦ ទៅ ០៧នាក់ទៀត បានជិះម៉ូតូចំនួន ០៦គ្រឿង មកដល់កន្លែងកើតហេតុ ឃើញជនរងគ្រោះឈ្មោះ [redacted] សុផាន់ ភេទប្រុស អាយុ ២២ឆ្នាំ និងគ្នីគ្នាពីរនាក់ទៀត មានឈ្មោះ [redacted] ណារ៉ាក់ និងឈ្មោះ [redacted] ស៊ីណាន់ កំពុងជិះម៉ូតូ ០១គ្រឿង ម៉ាកហុងដា សេ១២៥ ពណ៌ខ្មៅពាក់ស្លាកលេខ កំពង់ស្ពឺ 1U-4860 និងមានកាន់ដាវមួយដើមផងនោះ ទើបក្រុមជនជាប់ចោទបានជិះម៉ូតូដេញកាប់ក្រុមជនរងគ្រោះតែម្ដង ដែលធ្វើឱ្យក្រុមជនរងគ្រោះភ័យ ហើយផ្ដួលម៉ូតូចោលរត់ចូលទៅក្នុងផ្ទះអ្នកភូមិ។ បន្ទាប់មកជនជាប់ចោទឈ្មោះ យ៉ាង បានកាប់ម៉ូតូរបស់ជនរងគ្រោះ រួចជនជាប់ចោទឈ្មោះ [redacted] វស្នី ហៅ ង៉ោល បានខឹងនឹងជនរងគ្រោះពេកក៏លើកម៉ូតូរបស់ជនរងគ្រោះបានជិះប្រហែល ២០០ម៉ែត្រ រួចក៏ផ្ដួលម៉ូតូចោលវិញ ហើយបក្ខពួករបស់ជនជាប់ចោទឈ្មោះ ធុង បានលើកម៉ូតូរបស់ជនរងគ្រោះជិះបន្តឌុបឈ្មោះ [redacted] ហ៉េង ទៅផ្ទះ រួចពួកគេក៏បែងចែកផ្លូវគ្នាទៅបាត់អស់ទៅ។ លុះឈ្មោះ [redacted] វស្នី ស្នែកឡើងសមត្ថកិច្ចបានស្រាវជ្រាវឃាត់ខ្លួនជនជាប់ចោទឈ្មោះ [redacted] វ៉ែង ហៅ ញ៉ាញ់ ហៅ ង៉ោល និងឈ្មោះ [redacted] ហ៉េង មកសាកសួររួចកសាងសំណុំរឿងបញ្ជូនមកអយ្យការខេត្តកំពង់ស្ពឺ ចាត់ការតាមនីតិវិធីច្បាប់។



Scanned with CamScanner

**-បានឃើញ** របាយការណ៍សំយោគលេខ:១៨/២៣ ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២៣ របស់ការិយាល័យនគរបាលព្រហ្មទណ្ឌកំរិតធ្ងន់ នៃស្នងការដ្ឋាននគរបាលខេត្តកំពង់ស្ពឺ។

**-បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ:**១១១ អ.យ/២៣** ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២៣ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកំពង់ស្ពឺ។

**-បានឃើញ** ដីកាសន្និដ្ឋានស្ថាពរលេខ:**៩៨៤ ដ.ស.ព/២៣** ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២៣ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកំពង់ស្ពឺ។

**-បានឃើញ** ដីកាដំណោះស្រាយលេខ:**៩៦៨** ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកំពង់ស្ពឺ។

**-បានឃើញ** ដីកាចាត់តាំងសមាសភាពក្រុមប្រឹក្សាជំនុំជម្រះលេខ:**១២៧១ ដចជ.រប/២៣** ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០២៣ របស់ឯកឧត្តមប្រធានសាលាដំបូងខេត្តកំពង់ស្ពឺ។

## <u>នាពេលសវនាការ</u>

-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **វស្នី** ហៅ **ឆោល** នាពេលសវនាការបានឆ្លើយថា: កាលពីថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២៣ វេលាម៉ោងប្រហែល ០១ និង ០០ នាទីយប់ ខ្លួន និងបក្ខពួកមានគ្នាប្រហែលជាង ១០នាក់ មានឈ្មោះ [redacted] ហ៊ង ឈ្មោះ [redacted] វែង ឈ្មោះ ធុង ឈ្មោះ ឆានី ឈ្មោះ យ៉ាង ឈ្មោះ ខ្មៅ និង ០៦ទៅ ០៧នាក់ទៀតមិនស្គាល់ (ដោយសារទើបតែដើរជាមួយគ្នា) បានជិះម៉ូតូចេញពីវាយគ្នានៅភូមិបន្ទាយខ្មែរ រួចជិះម៉ូតូតាមផ្លូវចូលភូមិស្រែអូរ ដោយមានម៉ូតូចំនួន ០៦គ្រឿង ដើម្បីទៅមើលគ្នាដែលម៉ូតូអស់សាំង។ ពេលនោះឈ្មោះ ឆានី មានកាន់កាំបិតផ្គាក់មួយដើម ជិះម៉ូតូជាមួយម្នាក់ទៀត(ភ្លេច) ហើយឈ្មោះ យ៉ាង មានកាន់កាំបិតប៉ុងតោមួយដើម ជិះម៉ូតូជាមួយម្នាក់ទៀត(ភ្លេច) ចំណែកខ្លួនជិះម៉ូតូជាមួយឈ្មោះ [redacted] វែង ដោយខ្លួនជាអ្នកឌុប ហើយខ្លួន និងឈ្មោះ [redacted] វែង មិនមានអាវុធនោះទេ។ ពេលធ្វើដំណើរតាមផ្លូវក្នុងភូមិស្រែអូរ ឃុំពាំងល្វា ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ ស្រាប់តែមានមនុស្សប្រុស ០៣នាក់ មិនដែលស្គាល់ជិះម៉ូតូ ០១គ្រឿង ម៉ាកហុងដាសេ១២៥ ពណ៌ខ្មៅ ស៊េរីឆ្នាំ២០២២ (មិនដឹងថាមានស្លាកលេខ ឬអត់នោះទេ) ពីកើតទៅលិច ហើយមនុស្សប្រុសម្នាក់ដែលជិះក្រោយគេមានកាន់ដាវ ភ្លាមនោះក្រុមខ្លួនជិះដេញតាមពីក្រោយដោយមិនដឹងថាដេញតាម ដើម្បីអ្វីនោះទេ ហើយខ្លួនក៏បានជិះតាមគេដែរ។ បន្ទាប់មកជនរងគ្រោះជិះបានប្រហែល ១០០ម៉ែត្រ ជនរងគ្រោះទាំង០៣ បានផ្តួលម៉ូតូរត់ និងរើសដុំថ្មគប់សំដៅមកលើក្រុមពួកខ្លួន តែមិនត្រូវនោះទេ ហើយបក្ខពួកខ្លួនមានគ្នាប្រហែល ០៥ ទៅ ០៦នាក់ បានចុះពីលើម៉ូតូរត់ដេញតាមជនរងគ្រោះ តែពេលនោះមើលមិនសូវច្បាស់ថា នរណាគេខ្លះនោះទេ ដោយសារយប់ងងឹត រួចជនរងគ្រោះក៏បានរត់ចោលម៉ូតូអស់។ បន្ទាប់មកទៀតឈ្មោះ យ៉ាង និងឈ្មោះ ឆានី បានយកកាំបិតផ្គាក់និងប៉ុងតោទៅកាប់ម៉ូតូរបស់ជនរងគ្រោះ លុះពេលពួកគេកាប់រួច ខ្លួនក៏បានលើកម៉ូតូរបស់ជនរងគ្រោះជិះចេញទៅលិចបានប្រហែល ១០០ ម៉ែត្រ ក៏ផ្តួលម៉ូតូរបស់ជនរងគ្រោះចោលនៅលើថ្នល់។ រួចខ្លួនក៏បានឡើងជិះម៉ូតូជាមួយឈ្មោះ [redacted] វែង ត្រឡប់ទៅផ្ទះនៅភូមិបន្ទាយខ្មែរ ចំណែកឯម៉ូតូជនរងគ្រោះមិនដឹងនរណាយកនោះទេ។ លុះស្អែកឡើងម៉ោង ០៩ព្រឹក សមត្ថកិច្ចបានទៅឃាត់ខ្លួននៅផ្ទះតែម្តង។ ខ្លួនជិះម៉ូតូចេញពីភូមិបន្ទាយខ្មែរ សំដៅទៅស្រែអូរ ដើម្បីទៅយកមិត្តភក្តិដែលជិះម៉ូតូអស់សាំង ហើយពុំមានបំណងទៅប្លន់យកម៉ូតូរបស់អ្នកដំណើរតាមផ្លូវនោះទេ។



Scanned with CamScanner

-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] វែង ហៅ ញ៉ាញ់ នាពេលសវនាការបានឆ្លើយថា: កាលពីថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២៣ វេលាម៉ោងប្រហែល ០១ និង ០០នាទីយប់ ខ្លួន និងបក្ខពួកមានគ្នាប្រហែលជាង ១០នាក់ មានឈ្មោះ [redacted] ហ៑ង ឈ្មោះ [redacted] រស្មី ហៅ ដោល ឈ្មោះ ឆានី ឈ្មោះ យ៉ាង ឈ្មោះ ខ្មៅ និង ០៦ ទៅ ០៧នាក់ទៀតមិនស្គាល់(ដោយសារទើបតែដើរជាមួយគ្នា) បានជិះម៉ូតូចេញពីវាយគ្នានៅភូមិបន្ទាយខ្មែរ ជិះម៉ូតូតាមផ្លូវចូលភូមិស្រែអូរ ដោយមានម៉ូតូចំនួន ០៦គ្រឿង ដើម្បីជូនគ្នាត្រឡប់ទៅផ្ទះ។ ពេលនោះឈ្មោះ ឆានី មានកាន់កាំបិតផ្គាក់មួយដើម អ្នកផ្សេងមិនដឹងទេ ដោយសារមើលមិនច្បាស់ ចំណែកខ្លួនជិះម៉ូតូជាមួយឈ្មោះ [redacted] រស្មី ដោយខ្លួនជាអ្នកឌុប ហើយខ្លួន និងឈ្មោះ [redacted] រស្មី មិនមានអាវុធនោះទេ។ ពេលធ្វើដំណើរតាមផ្លូវក្នុងភូមិស្រែអូរ ឃុំពាំងល្វា ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ ស្រាប់តែមានមនុស្សប្រុស ០៣នាក់ មិនដែលស្គាល់ ជិះម៉ូតូ ០១គ្រឿង ម៉ាកហុងដា សេ ១២៥ ពណ៌ខ្មៅ ស៊េរីឆ្នាំ២០២២ មិនចាំស្លាកលេខ ជិះពីកើតទៅលិច ហើយមនុស្សប្រុសម្នាក់ដែលជិះក្រោយគេមានកាន់ដាវ និងម្នាក់ជិះកណ្តាលកាន់ដុំថ្ម ភ្លាមនោះក្រុមខ្លួនជិះដេញតាមពីក្រោយ ដើម្បីដេញវាយ និងកាប់ដោយគិតថា ពួកនោះជាក្រុមដែលទើបតែឈ្លោះគ្នាជាមួយក្រុមខ្លួននៅចំណុចភូមិបន្ទាយខ្មែរ។ បន្ទាប់មកជនរងគ្រោះជិះបានប្រហែល ១០០ម៉ែត្រ ជនរងគ្រោះទាំង០៣ បានផ្តួលម៉ូតូ និងរើសដុំថ្មគប់សំដៅមកលើក្រុមពួកខ្លួន តែមិនត្រូវនោះទេ ហើយបក្ខពួកខ្លួនមានគ្នាប្រហែល ០៥ ទៅ ០៦នាក់(មិនស្គាល់ឈ្មោះ) បានចុះពីលើម៉ូតូរត់ដេញតាមជនរងគ្រោះ រួចជនរងគ្រោះក៏បានរត់ចោលម៉ូតូអស់ ពេលនោះខ្លួននៅលើម៉ូតូ។ បន្ទាប់មកទៀតឈ្មោះ យ៉ាង និងឈ្មោះ ឆានី បានយកកាំបិតផ្គាក់ និងប៊ុងតោទៅកាប់ម៉ូតូរបស់ជនរងគ្រោះ លុះពេលពួកគេកាប់រួច ឈ្មោះ [redacted] រស្មី បានចុះពីលើម៉ូតូខ្លួនទៅលើកម៉ូតូរបស់ជនរងគ្រោះជិះចេញទៅលិចបានប្រហែល ១០០ម៉ែត្រ ក៏ផ្តួលម៉ូតូរបស់ជនរងគ្រោះចោលនៅលើថ្នល់ ហើយឈ្មោះ ធុង និងឈ្មោះ [redacted] ហ៑ង បានលើកម៉ូតូជិះយកទៅបាត់ មិនដឹងយកទៅណានោះទេ។ រួចខ្លួនក៏បានឡើងជិះម៉ូតូជាមួយឈ្មោះ [redacted] រស្មី ត្រឡប់ទៅផ្ទះនៅភូមិបន្ទាយខ្មែរ។ លុះស្អែកឡើងម៉ោង ០៩ព្រឹក ខ្លួនបានជូនឈ្មោះ ពែក ទៅផ្ទះស្ថិតនៅភូមិសំបួរ ឃុំជើងរាស់ ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ សមត្ថកិច្ចបានទៅឃាត់ខ្លួនតែម្តង។ ខ្លួនជិះម៉ូតូចេញពីភូមិបន្ទាយខ្មែរ សំដៅទៅភូមិស្រែអូរ ដើម្បីជូនមិត្តភក្តិទៅផ្ទះ ពុំមានបំណងទៅប្លន់យកម៉ូតូរបស់អ្នកដំណើរតាមផ្លូវនោះទេ។

-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ហ៑ង នាពេលសវនាការបានឆ្លើយថា: កាលពីថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២៣ វេលាម៉ោងប្រហែល ០១ និង ០០នាទីយប់ ខ្លួន និងបក្ខពួកមានគ្នាប្រហែលជាង ១០នាក់ មានឈ្មោះ [redacted] វែង ឈ្មោះ [redacted] រស្មី ហៅ ដោល ឈ្មោះ ធុង និង ១០នាក់ទៀតភ្លេចឈ្មោះ បានជិះម៉ូតូចេញពីភូមិបន្ទាយខ្មែរ ជិះម៉ូតូតាមផ្លូវចូលភូមិស្រែអូរ ដោយមានម៉ូតូចំនួន ០៦គ្រឿង ដើម្បីជូនគ្នាត្រឡប់ទៅផ្ទះ។ ពេលនោះខ្លួនមិនដឹងថានរណាខ្លះមានអាវុធនោះទេ ហើយខ្លួនក៏ពុំមានអាវុធដែរ ខ្លួនជិះម៉ូតូជាមួយឈ្មោះ ធុង ដោយឈ្មោះ ធុង ជាអ្នកឌុប ហើយម៉ូតូនោះជារបស់ខ្លួន ម៉ាកសង់សេ១២៥ ស៊េរីឆ្នាំ២០១០ ឡើងស៊េរីឆ្នាំ២០១៨ ពាក់ស្លាកលេខមិនចាំ។ ពេលធ្វើដំណើរតាមផ្លូវក្នុងភូមិស្រែអូ ឃុំពាំងល្វា ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ ស្រាប់តែមានមនុស្សប្រុស ០៣នាក់ មិនដែលស្គាល់ជិះម៉ូតូ ០១គ្រឿង ម៉ាកហុងដា សេ១២៥ ពណ៌ខ្មៅ ស៊េរីឆ្នាំ២០២២ មិនចាំស្លាកលេខ ជិះពីកើតទៅលិច ភ្លាមនោះក្រុមខ្លួនជិះដេញតាមពីក្រោយ ដើម្បីដេញវាយ និងកាប់ដោយគិតថា ពួកនោះជាក្រុមដែល ទើបតែឈ្លោះគ្នាជាមួយក្រុមខ្លួននៅចំណុចភូមិបន្ទាយខ្មែរ។ បន្ទាប់មកជនរងគ្រោះជិះបានប្រហែល ២០០ម៉ែត្រ ជនរងគ្រោះទាំង០៣ បានផ្តួលម៉ូតូរត់ និងរើសដុំថ្មគប់សំដៅមកលើក្រុមពួកខ្លួន តែមិនដឹងថាត្រូវគ្នារបស់ខ្លួនឬអត់នោះទេ



Scanned with CamScanner

ហើយបក្ខពួកខ្លួនមានគ្នាប្រហែល ០៨នាក់ (មើលមិនច្បាស់ដោយសារងងឹត) បានចុះពីលើម៉ូតូរត់ដេញតាមជនរងគ្រោះ រួចជនរងគ្រោះក៏បានរត់ចោលម៉ូតូអស់ ពេលនោះខ្លួននៅអង្គុយលើម៉ូតូរបស់ខ្លួន។ បន្ទាប់មកទៀតគ្នាខ្លួនប្រហែល ០៨នាក់ បានយកកាំបិត និងដំបងទៅវាយ និងកាប់ម៉ូតូរបស់ជនរងគ្រោះ លុះពេលពួកគេកាប់រួច ឈ្មោះ [redacted] រស្មី បានចុះពីលើម៉ូតូទៅលើកម៉ូតូរបស់ជនរងគ្រោះជិះចេញទៅលិចបានប្រហែល ១០០ម៉ែត្រ ក៏ផ្ដួលម៉ូតូរបស់ជនរងគ្រោះចោលនៅលើថ្នល់ ហើយគ្នារបស់ខ្លួន ០២នាក់មិនស្គាល់ឈ្មោះ ក៏បានលើកម៉ូតូជនរងគ្រោះជិះ ហើយខ្លួនក៏បានហៅពួកគេឱ្យជិះយកម៉ូតូរបស់ជនរងគ្រោះទៅទុកនៅផ្ទះយាយ ហើយខ្លួន និងឈ្មោះ ធុង ក៏បានជិះម៉ូតូរបស់ខ្លួនទៅផ្ទះ នៅភូមិទឹកលង ឃុំរុងរឿង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ។ ពេលទៅដល់ផ្ទះយាយរបស់ខ្លួន គ្នាខ្លួន ០២នាក់នោះ ក៏បានទុកម៉ូតូជនរងគ្រោះនៅផ្ទះយាយរបស់ខ្លួន ហើយ ០២នាក់នោះក៏បានជិះម៉ូតូគុបជ្រុងរបស់យាយខ្លួនត្រឡប់ទៅផ្ទះគេវិញ ចំណែកខ្លួន និងឈ្មោះ ធុង បានជិះម៉ូតូរបស់ខ្លួនជាមួយគ្នា ដើម្បីជូនឈ្មោះ ធុង ទៅផ្ទះ ស្ថិតនៅភូមិច្រងែ ឃុំជើងរាស់ ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ ពេលជូនឈ្មោះ ធុង ទៅផ្ទះហើយ ខ្លួនក៏បានជិះម៉ូតូរបស់ខ្លួនត្រឡប់មកផ្ទះវិញម្នាក់ឯងស្ថិតនៅក្នុងភូមិច្រងែដែរ។ ខ្លួនជិះម៉ូតូចេញពីភូមិបន្ទាយខ្មែរ សំដៅទៅភូមិស្រែអូរ ដើម្បីជូនមិត្តភក្តិទៅផ្ទះ ហើយពុំមានបំណងទៅប្លន់យកម៉ូតូរបស់អ្នកដំណើរតាមផ្លូវនោះទេ ប៉ុន្តែពេលជិះម៉ូតូជួបជនរងគ្រោះទាំង ០៣នាក់ ដោយគិតថា ជាក្រុមដែលទើបតែឈ្លោះគ្នាជាមួយក្រុមខ្លួននៅចំណុចភូមិបន្ទាយខ្មែរទើបខ្លួន និងបក្ខពួកនាំគ្នាជិះតាមដេញវាយ និងកាប់តែម្តងទៅ ប៉ុន្តែវាយនិងកាប់មិនបាន ដោយសារជនរងគ្រោះបានរត់។

-តាមអំណានចម្លើយរបស់ដើមបណ្ដឹងឈ្មោះ [redacted] **សុផាន់** បានបញ្ជាក់ថា: កាលពីថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ ២០២៣ វេលាម៉ោង ០០ និង ៥០នាទី ខ្លួន និងមិត្តភក្តិ ០២នាក់ ឈ្មោះ[redacted]ណារ៉ាក់ ឈ្មោះ [redacted] ស៊ីណាន់ ដោយជិះម៉ូតូរបស់ខ្លួន ម៉ាកហុងដា សេ១២៥ ស៊េរី ២០២២ ពណ៌ខ្មៅ ស្លាកលេខ កំពង់ស្ពឺ 1U-4860 ចេញពីភូមិព្រៃព្រាន ដើម្បីត្រឡប់ទៅផ្ទះវិញ ពេលជិះដល់ចំណុចកើតហេតុ ស្រាប់តែមានក្រុមជនសង្ស័យ ០១ក្រុម មិនស្គាល់ជិះម៉ូតូ ០៦ទៅ ០៧គ្រឿង បានស្រែកថា កាប់អា ០៣នាក់ លេងសិន ឮសូរបែបនេះខ្លួនបើកម៉ូតូទៅមុខទៀត ហើយពួកវាបានជិះដេញតាមពីក្រោយដល់ភូមិស្រែអូរ ពួកវាយកដុំថ្មគប់ត្រូវក្បាលខ្លួន ហើយខ្លួនបានផ្ដួលម៉ូតូរត់ចូលផ្ទះអ្នកភូមិ ចំណែកម៉ូតូខ្លួនត្រូវបានពួកវាកាប់បំផ្លាញ និងលើកជិះយកទៅបាត់។

## <u>សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ</u>

-តំណាងអយ្យការបានធ្វើសេចក្ដីសន្និដ្ឋានថា៖ ឆ្លងតាមការពិភាក្សាដេញដោល ក្រោយពីបានស្ដាប់ចម្លើយសារភាពរបស់ជនជាប់ចោទ តាមអំណានចម្លើយរបស់ដើមបណ្ដឹង និងឯកសារផ្សេងៗនៅក្នុងសំណុំរឿងឃើញថាជនជាប់ចោទពិតជាបានប្រព្រឹត្ត បទល្មើស **កំហែងយកមានស្ថានទម្ងន់ទោសដោយប្រើប្រាស់អាវុធ** ពិតប្រាកដមែន។ ហេតុនេះហើយ តំណាងអយ្យការនៅតែតម្កល់ការចោទប្រកាន់លើជនជាប់ចោទឈ្មោះ [redacted] **រស្មី** ហៅ **ង៉ោល** ឈ្មោះ [redacted] **វែង** ហៅ **ញ៉ាញ់** និងឈ្មោះ [redacted] **ហ៊ង** ពីបទ: **កំហែងយកមានស្ថានទម្ងន់ទោសដោយប្រើប្រាស់អាវុធ** ប្រព្រឹត្តនៅចំណុចភូមិស្រែអូរ ឃុំពាំងល្វា ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ តាមបញ្ញត្តិមាត្រា**៣៦៣** និងមាត្រា**៣៦៦** នៃក្រមព្រហ្មទណ្ឌ តាមដីកាសន្និដ្ឋានស្ថាពរលេខ:**៩៨៤ ដ.ស.ព/២៣** ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ**២០២៣**។



Scanned with CamScanner

## សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] រស្មី ហៅ ង៉ោល និងឈ្មោះ [redacted] វ៉េង ហៅ ញ៉ាញ់ ធ្វើសេចក្តីសន្និដ្ឋានថាៈ ដោយកូនក្តីខ្លួនបានឆ្លើយសារភាពហើយ ម្យ៉ាងទៀតដោយសារស្ថានភាពយល់ដឹងគាត់នៅក្មេងនៅឡើយ មិនអាចពិចារណាបានច្បាស់លាស់ ស្នើរសុំឱ្យតុលាការផ្តល់ស្ថានសម្រាលឱ្យកូនក្តីខ្លួនផង។

-លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ហ៊ាង ធ្វើសេចក្តីសន្និដ្ឋានថាៈ កូនក្តីខ្លួនពិតជាបានចូលរួមក៏ប៉ុន្តែដោយកូនក្តីខ្លួនមិនមានអាវុធ ដើម្បីចូលរួមដណ្តើមយកម៉ូតូដោយកំហែងយកទេ ហើយកូនក្តីខ្លួនគ្រាន់តែចូលរួមនៅក្នុងការកាប់ម៉ូតូនោះទេ ហេតុនេះខ្លួនស្នើសុំឱ្យតុលាការសម្រេចប្តូរបទចោទពីបទៈ កំហែងយកមានស្ថានទម្ងន់ទោសដោយប្រើប្រាស់អាវុធ មកបទៈកំហែងយក វិញ។

## សំដីចុងក្រោយរបស់ជនជាប់ចោទ

-ជនជាប់ចោទឈ្មោះ [redacted] រស្មី ហៅ ង៉ោល បាននិយាយសំដីចុងក្រោយបង្អស់ថា៖ សំណូមពរសុំឱ្យតុលាការបន្ធូរបន្ថយទោស។

-ជនជាប់ចោទឈ្មោះ [redacted] វ៉េង ហៅ ញ៉ាញ់ បាននិយាយសំដីចុងក្រោយបង្អស់ថា៖ សំណូមពរសុំឱ្យតុលាការបន្ធូរបន្ថយទោស។

-ជនជាប់ចោទឈ្មោះ [redacted] ហ៊ាង បាននិយាយសំដីចុងក្រោយបង្អស់ថា៖ សំណូមពរសុំឱ្យតុលាការបន្ធូរបន្ថយទោស។

## តុលាការ

-ស្តាប់ និងសួរចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] រស្មី ហៅ ង៉ោល ឈ្មោះ [redacted] វ៉េង ហៅ ញ៉ាញ់ និងឈ្មោះ [redacted] ហ៊ាង។

-តាមអំណានចម្លើយរបស់ដើមបណ្តឹងឈ្មោះ [redacted] សុផាន់

-ស្តាប់ក្រឡាបញ្ជីអានរបាយការណ៍ និងកំណត់ហេតុផ្សេងៗទៀត

-ស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-ស្តាប់ជនជាប់ចោទសំណូមពរផ្សេងៗ

-ក្រោយពីបានពិនិត្យភស្តុតាង និងពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

១.កាលពីថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២៣ វេលាម៉ោង ០១ និង ០០នាទីព្រឹក ស្ថិតនៅភូមិស្រែអូរ ឃុំពាំងល្វា ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ ជនជាប់ចោទមួយក្រុមមានឈ្មោះ [redacted] វ៉េង ហៅ ញ៉ាញ់ ភេទប្រុស អាយុ ១៨ឆ្នាំ ឈ្មោះ [redacted] រស្មី ហៅ ង៉ោល ភេទប្រុស អាយុ ១៥ឆ្នាំ ឈ្មោះ [redacted] ហ៊ាង ភេទប្រុស អាយុ ២៣ឆ្នាំ ឈ្មោះ ធុង ភេទប្រុស អាយុប្រហែល ១៩ឆ្នាំ ឈ្មោះ ឆានី ភេទប្រុស អាយុ ១៧ឆ្នាំ ឈ្មោះ យ៉ាង ភេទប្រុស អាយុ ១៨ឆ្នាំ (មានកាន់កាំបិតផ្គាក់) ឈ្មោះ វ៉ុង ភេទប្រុស អាយុ ១៩ឆ្នាំ និងបក្ខពួកប្រហែល ០៦ ទៅ ០៧នាក់ទៀត បានជិះម៉ូតូចំនួន ០៦គ្រឿង មកដល់កន្លែងកើតហេតុ ឃើញជនរងគ្រោះឈ្មោះ [redacted] សុផាន់ ភេទប្រុស អាយុ ២២ឆ្នាំ និងគ្នីគ្នាពីរនាក់ទៀត មានឈ្មោះ [redacted] ណារ៉ាក់ និងឈ្មោះ [redacted] ស៊ីណាន់ កំពុងជិះម៉ូតូ ០១គ្រឿង ម៉ាកហុងដា សេ១២៥ ពណ៌ខ្មៅ



Scanned with CamScanner

ពាក់ស្លាកលេខ កំពង់ស្ពឺ 1U-4860 និងមានកាន់ដាវមួយដើមផងនោះ ទើបក្រុមជនជាប់ចោទបានជិះម៉ូតូដេញកាប់ក្រុមជនរងគ្រោះតែម្តង ដែលធ្វើឱ្យក្រុមជនរងគ្រោះភ័យ ហើយផ្តួលម៉ូតូចោលរត់ចូលទៅក្នុងផ្ទះអ្នកភូមិ។ បន្ទាប់មកជនជាប់ចោទឈ្មោះ យ៉ាង បានកាប់ម៉ូតូរបស់ជនរងគ្រោះ រួចជនជាប់ចោទឈ្មោះ [redacted] វស្នី ហៅ ង៉ោល បានខឹងនឹងជនរងគ្រោះពេកក៏លើកម្ចូតូរបស់ជនរងគ្រោះបានជិះប្រហែល ២០០ម៉ែត្រ រួចក៏ផ្តួលម៉ូតូចោលវិញ ហើយបក្ខពួករបស់ជនជាប់ចោទឈ្មោះ ធុង បានលើកម៉ូតូរបស់ជនរងគ្រោះជិះបន្តឱ្យឈ្មោះ [redacted] ហ៊ាង ទៅផ្ទះ រួចពួកគេក៏បែងចែកផ្លូវគ្នាទៅបាត់អស់ទៅ ប្រាកដមែន។

**២**.តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **វស្នី** ហៅ **ង៉ោល** បានឆ្លើយថា: កាលពីថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ ២០២៣ វេលាម៉ោងប្រហែល ០១ និង ០០ នាទីយប់ ខ្លួន និងបក្ខពួកមានគ្នាប្រហែលជាង ១០នាក់ មានឈ្មោះ [redacted] ហ៊ាង ឈ្មោះ [redacted] វែង ឈ្មោះ ធុង ឈ្មោះ ឆានី ឈ្មោះ យ៉ាង ឈ្មោះ ខ្មៅ និង ០៦ទៅ ០៧នាក់ទៀត មិនស្គាល់ (ដោយសារទើបតែដើរជាមួយគ្នា) បានជិះម៉ូតូចេញពីវាយគ្នានៅភូមិបន្ទាយខ្មែរ រួចជិះម៉ូតូតាមផ្លូវចូលភូមិស្រែអូរ ដោយមានម៉ូតូចំនួន ០៦គ្រឿង ដើម្បីទៅមើលគ្នាដែលម៉ូតូអស់សាំង។ ពេលនោះឈ្មោះ ឆានី មានកាន់កាំបិតផ្គាក់មួយដើម ជិះម៉ូតូជាមួយម្នាក់ទៀត(ភ្លេច) ហើយឈ្មោះ យ៉ាង មានកាន់កាំបិតប៊ុងតោមួយដើម ជិះម៉ូតូជាមួយម្នាក់ទៀត(ភ្លេច) ចំណែកខ្លួនជិះម៉ូតូជាមួយឈ្មោះ [redacted] វែង ដោយខ្លួនជាអ្នកឌុប ហើយខ្លួន និងឈ្មោះ [redacted] វែង មិនមានអាវុធនោះទេ។ ពេលធ្វើដំណើរតាមផ្លូវក្នុងភូមិស្រែអូរ ឃុំពាំងល្វា ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ ស្រាប់តែមានមនុស្សប្រុស ០៣នាក់ មិនដែលស្គាល់ជិះម៉ូតូ ០១គ្រឿង ម៉ាកហុងដាសេ១២៥ ពណ៌ខ្មៅ ស៊េរីឆ្នាំ២០២២ (មិនដឹងថាមានស្លាកលេខ ឬអត់នោះទេ) ពីកើតទៅលិច ហើយមនុស្សប្រុសម្នាក់ដែលជិះក្រោយគេមានកាន់ដាវ ភ្លាមនោះក្រុមខ្លួនជិះដេញតាមពីក្រោយដោយមិនដឹងថាដេញតាម ដើម្បីអ្វីនោះទេ ហើយខ្លួនក៏បានជិះតាមគេដែរ។ បន្ទាប់មកជនរងគ្រោះជិះបានប្រហែល ១០០ម៉ែត្រ ជនរងគ្រោះទាំង០៣ បានផ្តួលម៉ូតូរត់ និងរើសដុំ ថ្មគប់សំដៅមកលើក្រុមពួកខ្លួនតែមិនត្រូវនោះទេ ហើយបក្ខពួកខ្លួនមានគ្នាប្រហែល ០៥ ទៅ ០៦នាក់ បានចុះពីលើម៉ូតូរត់ដេញតាមជនរងគ្រោះតែពេលនោះមើលមិនសូវច្បាស់ថា នរណាគេខ្លះនោះទេ ដោយសារយប់ងងឹត រួចជនរងគ្រោះក៏បានរត់ចោលម៉ូតូអស់។ បន្ទាប់មកទៀតឈ្មោះ យ៉ាង និងឈ្មោះ ឆានី បានយកកាំបិតផ្គាក់ និងប៊ុងតោទៅកាប់ម៉ូតូរបស់ជនរងគ្រោះលុះពេលពួកគេកាប់រួច ខ្លួនក៏បានលើកម៉ូតូរបស់ជនរងគ្រោះជិះចេញទៅលិចបានប្រហែល ១០០ម៉ែត្រ ក៏ផ្តួលម៉ូតូរបស់ជនរងគ្រោះចោលនៅលើថ្នល់។ រួចខ្លួនក៏បានឡើងជិះម៉ូតូជាមួយឈ្មោះ [redacted] វែង ត្រឡប់ទៅផ្ទះនៅភូមិបន្ទាយខ្មែរ ចំណែកឯម៉ូតូជនរងគ្រោះមិនដឹងនរណាយកនោះទេ។ លុះស្អែកឡើងម៉ោង ០៩ព្រឹក សមត្ថកិច្ចបានទៅឃាត់ខ្លួននៅផ្ទះតែម្តង។ ខ្លួនជិះម៉ូតូចេញពីភូមិបន្ទាយខ្មែរ សំដៅទៅស្រែអូរ ដើម្បីទៅយកមិត្តភក្តិដែលជិះម៉ូតូអស់សាំង ហើយពុំមានបំណងទៅប្លន់យកម៉ូតូរបស់អ្នកដំណើរតាមផ្លូវនោះទេ។

៣.តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **វែង** ហៅ **ញ៉ាញ់** បានឆ្លើយថា: កាលពីថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ ២០២៣ វេលាម៉ោងប្រហែល ០១ និង ០០នាទីយប់ ខ្លួន និងបក្ខពួកមានគ្នាប្រហែលជាង ១០នាក់ មានឈ្មោះ [redacted] ហ៊ាង ឈ្មោះ [redacted] វស្នី ហៅ ង៉ោល ឈ្មោះ ឆានី ឈ្មោះ យ៉ាង ឈ្មោះ ខ្មៅ និង ០៦ ទៅ ០៧នាក់ទៀតមិនស្គាល់ (ដោយសារទើបតែដើរជាមួយគ្នា) បានជិះម៉ូតូចេញពីវាយគ្នានៅភូមិបន្ទាយខ្មែរ ជិះម៉ូតូតាមផ្លូវចូលភូមិស្រែអូរ ដោយមានម៉ូតូចំនួន ០៦គ្រឿង ដើម្បីជូនគ្នាត្រឡប់ទៅផ្ទះ។ ពេលនោះឈ្មោះ ឆានី មានកាន់កាំបិតផ្គាក់មួយដើម អ្នកផ្សេងមិនដឹងទេ ដោយសារមើលមិនច្បាស់ ចំណែកខ្លួនជិះម៉ូតូជាមួយឈ្មោះ [redacted] វស្នី ដោយខ្លួនជាអ្នកឌុប

ហើយខ្លួន និងឈ្មោះ [redacted] វស្នី មិនមានអាវុធនោះទេ។ ពេលធ្វើដំណើរតាមផ្លូវក្នុងភូមិស្រែអូរ ឃុំពាំងល្វា ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ ស្រាប់តែមានមនុស្សប្រុស ០៣នាក់ មិនដែលស្គាល់ ជិះម៉ូតូ ០១គ្រឿង ម៉ាកហុងដា សេ១២៥ ពណ៌ខ្មៅ ស៊េរីឆ្នាំ២០២២ មិនចាំស្លាកលេខ ជិះពីកើតទៅលិច ហើយមនុស្សប្រុសម្នាក់ដែលជិះក្រោយគេមានកាន់ដាវ និងម្នាក់ជិះកណ្តាលកាន់ដុំថ្ម ភ្លាមនោះក្រុមខ្លួនជិះដេញតាមពីក្រោយ ដើម្បីដេញវាយ និងកាប់ដោយគិតថា ពួកនោះជាក្រុមដែលទើបតែឈ្លោះគ្នាជាមួយក្រុមខ្លួននៅចំណុចភូមិបន្ទាយខ្មែរ។ បន្ទាប់មកជនរងគ្រោះជិះបានប្រហែល ១០០ម៉ែត្រ ជនរងគ្រោះទាំង០៣ បានផ្តួលម៉ូតូ និងរើសដុំថ្មគប់សំដៅមកលើក្រុមពួកខ្លួនតែមិនត្រូវនោះទេ ហើយបក្ខពួកខ្លួនមានគ្នាប្រហែល ០៥ ទៅ ០៦នាក់(មិនស្គាល់ឈ្មោះ) បានចុះពីលើម៉ូតូរត់ដេញតាមជនរងគ្រោះ រួចជនរងគ្រោះក៏បានរត់ចោលម៉ូតូអស់ ពេលនោះខ្លួននៅលើម៉ូតូ។ បន្ទាប់មកទៀតឈ្មោះ យ៉ាង និងឈ្មោះ ឆានី បានយកកាំបិតផ្គាក់ និងប៉ុងតោទៅកាប់ម៉ូតូរបស់ជនរងគ្រោះ លុះពេលពួកគេកាប់រួច ឈ្មោះ [redacted] វស្នី បានចុះពីលើម៉ូតូខ្លួនទៅលើកម៉ូតូរបស់ជនរងគ្រោះជិះចេញទៅលិចបានប្រហែល១០០ម៉ែត្រ ក៏ផ្តួលម៉ូតូរបស់ជនរងគ្រោះចោលនៅលើថ្នល់ ហើយឈ្មោះ ធុង និងឈ្មោះ [redacted] ហ៉ាង បានលើកម៉ូតូជិះយកទៅបាត់ មិនដឹងយកនៅណានោះទេ។ រួចខ្លួនក៏បានឡើងជិះម៉ូតូជាមួយឈ្មោះ រឿន វស្នី ត្រឡប់ទៅផ្ទះនៅភូមិបន្ទាយខ្មែរ។ លុះស្អែកឡើងម៉ោង ០៩ព្រឹក ខ្លួនបានជូនឈ្មោះ ពែក ទៅផ្ទះស្ថិតនៅភូមិសំបួរ ឃុំជើងរាស់ ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ សមត្ថកិច្ចបានទៅឃាត់ខ្លួនតែម្តង។ ខ្លួនជិះម៉ូតូចេញពីភូមិបន្ទាយខ្មែរ សំដៅទៅភូមិស្រែអូរ ដើម្បីជូនមិត្តភក្តិទៅផ្ទះ ពុំមានបំណងទៅប្លន់យកម៉ូតូរបស់អ្នកដំណើរតាមផ្លូវនោះទេ។

៤.តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ហ៉ាង បានឆ្លើយថា: កាលពីថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២៣ វេលាម៉ោងប្រហែល ០១ និង ០០នាទីយប់ ខ្លួន និងបក្ខពួកមានគ្នាប្រហែលជាង ១០នាក់ មានឈ្មោះ [redacted] វែង ឈ្មោះ [redacted] វស្នី ហៅ ង៉ោល ឈ្មោះ ធុង និង ១០នាក់ទៀតភ្លេចឈ្មោះ បានជិះម៉ូតូចេញពីភូមិបន្ទាយខ្មែរ ជិះម៉ូតូតាមផ្លូវចូលភូមិស្រែអូរ ដោយមានម៉ូតូចំនួន ០៦គ្រឿង ដើម្បីជូនគ្នាត្រឡប់ទៅផ្ទះ។ ពេលនោះខ្លួនមិនដឹងថា នរណាខ្លះមានអាវុធនោះទេ ហើយខ្លួនក៏ពុំមានអាវុធដែរ ខ្លួនជិះម៉ូតូជាមួយឈ្មោះ ធុង ដោយឈ្មោះ ធុង ជាអ្នកឌុប ហើយម៉ូតូនោះជារបស់ខ្លួន ម៉ាកសង់សេ១២៥ ស៊េរីឆ្នាំ២០១០ ឡើងស៊េរីឆ្នាំ២០១៨ ពាក់ស្លាកលេខមិនចាំ។ ពេលធ្វើដំណើរតាមផ្លូវក្នុងភូមិស្រែអូ ឃុំពាំងល្វា ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ ស្រាប់តែមានមនុស្សប្រុស ០៣នាក់ មិនដែលស្គាល់ជិះម៉ូតូ ០១គ្រឿង ម៉ាកហុងដា សេ១២៥ ពណ៌ខ្មៅ ស៊េរីឆ្នាំ២០២២ មិនចាំស្លាកលេខ ជិះពីកើតទៅលិច ភ្លាមនោះក្រុមខ្លួនជិះដេញតាមពីក្រោយ ដើម្បីដេញវាយ និងកាប់ដោយគិតថា ពួកនោះជាក្រុមដែល ទើបតែឈ្លោះគ្នាជាមួយក្រុមខ្លួននៅចំណុចភូមិបន្ទាយខ្មែរ។ បន្ទាប់មកជនរងគ្រោះជិះបានប្រហែល ២០០ម៉ែត្រ ជនរងគ្រោះទាំង០៣ បានផ្តួលម៉ូតូរត់ និងរើសដុំថ្មគប់សំដៅមកលើក្រុមពួកខ្លួន តែមិនដឹងថាត្រូវគ្នារបស់ខ្លួនឬអត់នោះទេ ហើយបក្ខពួកខ្លួនមានគ្នាប្រហែល ០៨នាក់ (មើលមិនច្បាស់ដោយសារងងឹត) បានចុះពីលើម៉ូតូរត់ដេញតាមជនរងគ្រោះ រួចជនរងគ្រោះក៏បានរត់ចោលម៉ូតូអស់ ពេលនោះខ្លួននៅអង្គុយលើម៉ូតូរបស់ខ្លួន។ បន្ទាប់មកទៀតគ្នាខ្លួនប្រហែល ០៨នាក់បានយកកាំបិត និងដំបងទៅវាយ និងកាប់ម៉ូតូរបស់ជនរងគ្រោះ លុះពេលពួកគេកាប់រួច ឈ្មោះ [redacted] វស្នី បានចុះពីលើម៉ូតូទៅលើកម៉ូតូរបស់ជនរងគ្រោះជិះចេញទៅលិចបានប្រហែល ១០០ម៉ែត្រ ក៏ផ្តួលម៉ូតូរបស់ជនរងគ្រោះចោលនៅលើថ្នល់ ហើយគ្នារបស់ខ្លួន ០២នាក់មិនស្គាល់ឈ្មោះក៏បានលើកម៉ូតូជនរងគ្រោះជិះ ហើយខ្លួនក៏បានហៅពួកគេឱ្យជិះយកម៉ូតូរបស់ជនរងគ្រោះទៅទុកនៅផ្ទះយាយ ហើយខ្លួន និងឈ្មោះ ធុង ក៏បានជិះម៉ូតូរបស់ខ្លួនទៅផ្ទះ

នៅភូមិទឹកលង ឃុំរុងរឿង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ។ ពេលទៅដល់ផ្ទះយាយរបស់ខ្លួន គ្នាខ្លួន ០២នាក់នោះ ក៏បានទុកម៉ូតូជនរងគ្រោះនៅផ្ទះយាយរបស់ខ្លួន ហើយ ០២នាក់នោះ ក៏បានជិះម៉ូតូគុបជ្រុងរបស់យាយខ្លួនត្រឡប់ទៅផ្ទះគេវិញ ចំណែកខ្លួន និងឈ្មោះ ធុង បានជិះម៉ូតូរបស់ខ្លួនជាមួយគ្នា ដើម្បីជូនឈ្មោះ ធុង ទៅផ្ទះ ស្ថិតនៅភូមិច្រង៉ែ ឃុំជើងរាស់ ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ ពេលជូនឈ្មោះ ធុង ទៅផ្ទះហើយ ខ្លួនក៏បានជិះម៉ូតូរបស់ខ្លួនត្រឡប់មកផ្ទះវិញម្នាក់ឯងស្ថិតនៅក្នុងភូមិច្រង៉ែដែរ។ ខ្លួនជិះម៉ូតូចេញពីភូមិបន្ទាយខ្មែរ សំដៅទៅភូមិស្រែអូរ ដើម្បីជូនមិត្តភក្តិទៅផ្ទះ ហើយពុំមានបំណងទៅប្លន់យកម៉ូតូរបស់អ្នកដំណើរតាមផ្លូវនោះទេ ប៉ុន្តែពេលជិះម៉ូតូជួបជនរងគ្រោះទាំង ០៣នាក់ ដោយគិតថាជាក្រុមដែលទើបតែឈ្លោះគ្នាជាមួយក្រុមខ្លួននៅចំណុចភូមិបន្ទាយខ្មែរ ទើបខ្លួន និងបក្ខពួកនាំគ្នាជិះតាមដេញវាយ និងកាប់តែម្តងទៅ ប៉ុន្តែវាយនិងកាប់មិនបាន ដោយសារជនរងគ្រោះបានរត់។

៥.តាមអំណានចម្លើយរបស់ដើមបណ្តឹងឈ្មោះ [redacted] **សុផាន់** បានបញ្ជាក់ថាៈ កាលពីថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ ២០២៣ វេលាម៉ោង ០០ និង ៥០នាទី ខ្លួន និងមិត្តភក្តិ ០២នាក់ ឈ្មោះ [redacted] ណារ៉ាក់ ឈ្មោះ [redacted] ស៊ីណាន់ ដោយជិះម៉ូតូរបស់ខ្លួន ម៉ាកហុងដា សេ១២៥ ស៊េរី ២០២២ ពណ៌ខ្មៅ ស្លាកលេខ កំពង់ស្ពឺ 1U-4860 ចេញពីភូមិព្រៃព្រាន ដើម្បីត្រឡប់ទៅផ្ទះវិញ ពេលជិះដល់ចំណុចកើតហេតុ ស្រាប់តែមានក្រុមជនសង្ស័យ ០១ក្រុម មិនស្គាល់ជិះម៉ូតូ ០៦ទៅ ០៧គ្រឿង បានស្រែកថា កាប់អា ០៣នាក់ លេងសិន ឮសូរបែបនេះខ្លួនបើកម៉ូតូទៅមុខទៀត ហើយពួកវាបានជិះដេញតាមពីក្រោយដល់ភូមិស្រែអូរ ពួកវាយកដុំថ្មគប់ត្រូវក្បាលខ្លួន ហើយខ្លួនបានផ្តួលម៉ូតូរត់ចូលផ្ទះអ្នកភូមិ ចំណែកម៉ូតូខ្លួនត្រូវបានពួកវាកាប់បំផ្លាញ និងលើកជិះយកទៅបាត់។

**៦.**តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **វស្សី** ហៅ **ង៉ោល** ឈ្មោះ [redacted] **វ៉ែង** ហៅ **ញ៉ាញ់** និងឈ្មោះ [redacted] **ហ៊ង** អំណានចម្លើយរបស់ដើមបណ្តឹងឈ្មោះ [redacted] **សុផាន់** របាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ និងការពិនិត្យភស្តុតាងជាឯកសារនានាក្នុងសំណុំរឿងអាចកំណត់បានថា កាលពីថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២៣ ពិតជាមានករណី **កំហែងយក** កើតឡើងដែលបង្កឡើងដោយជនជាប់ចោទឈ្មោះ [redacted] **វស្សី** ហៅ **ង៉ោល** ភេទប្រុស អាយុ ១៥ឆ្នាំ ឈ្មោះ [redacted] **វ៉ែង** ហៅ **ញ៉ាញ់** ភេទប្រុស អាយុ ១៨ឆ្នាំ និងឈ្មោះ [redacted] **ហ៊ង** ភេទប្រុស អាយុ ២៤ឆ្នាំ ពិតប្រាកដមែន។ អង្គហេតុខាងលើនេះ ត្រូវបានច្បាប់បញ្ញត្តិថាជាបទល្មើស **កំហែងយក** តាមបញ្ញត្តិមាត្រា**៣៦៣** និងមាត្រា**៣៦៤** នៃក្រមព្រហ្មទណ្ឌ។

**៧.**បទចោទប្រកាន់លើជនជាប់ចោទឈ្មោះ [redacted] **វស្សី** ហៅ **ង៉ោល** ឈ្មោះ [redacted] **វ៉ែង** ហៅ **ញ៉ាញ់** និងឈ្មោះ [redacted] **ហ៊ង** ពីបទៈ **កំហែងយកមានស្ថានទម្ងន់ទោសដោយប្រើប្រាស់អាវុធ** ក៏បានបង្ហាញឱ្យឃើញថាមានវិមតិសង្ស័យជាច្រើន ដោយគ្មានភស្តុតាងគ្រប់គ្រាន់អាចបញ្ជាក់ថាជនជាប់ចោទបានប្រព្រឹត្តអំពើ**កំហែងយកមានស្ថានទម្ងន់ទោសដោយប្រើប្រាស់អាវុធ**ឡើយ។ តាមមាត្រា៣៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ វិមតិសង្ស័យត្រូវតែបានជាអត្ថប្រយោជន៍ដល់ជនជាប់ចោទជានិច្ច។

**៨.**គ្មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] **វស្សី** ហៅ **ង៉ោល** ឈ្មោះ [redacted] **វ៉ែង** ហៅ **ញ៉ាញ់** និងឈ្មោះ [redacted] **ហ៊ង** ពីបទៈ **កំហែងយកមានស្ថានទម្ងន់ទោសដោយប្រើប្រាស់អាវុធ** ប្រព្រឹត្តនៅចំណុចភូមិស្រែអូរ ឃុំពាំងល្វា ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២៣ តាមបញ្ញត្តិមាត្រា**៣៦៣** និងមាត្រា**៣៦៦** នៃក្រមព្រហ្មទណ្ឌ គប្បីសម្រេចប្តូរទៅជាបទៈ **កំហែងយក** តាមបញ្ញត្តិមាត្រា**៣៦៣** និងមាត្រា**៣៦៤** នៃ ក្រមព្រហ្មទណ្ឌ។



Scanned with CamScanner

៩.ដោយជនជាប់ចោទឈ្មោះ [redacted] **រស្មី** ហៅ **ម៉ោល** នៅជាអនីតិជននៅឡើយ ដូចនេះគប្បីតុលាការសម្រេចផ្តន្ទាទោសជនជាប់ចោទដោយគិតទៅលើឧត្តមប្រយោជន៍របស់កុមារ និងសម្រេចផ្អែកតាមមាត្រា១៦០ នៃក្រមព្រហ្មទណ្ឌ។

១០.នាពេលប្រព្រឹត្តបទល្មើសជនជាប់ចោទឈ្មោះ [redacted] **វ៉ែង** ហៅ **ញ៉ាញ់** និងឈ្មោះ [redacted] **ហ័ង** ជានីតិជន ជាជនមានស្មារតីគ្រប់គ្រាន់ និងសមត្ថភាពពេញលេញក្នុងការយល់ដឹងចំពោះអំពើប្រព្រឹត្តរបស់ខ្លួន និងលទ្ធផលតាមផ្លូវច្បាប់ ដូច្នេះត្រូវតែទទួលខុសត្រូវព្រហ្មទណ្ឌ។ អំពើប្រព្រឹត្តរបស់ជនជាប់ចោទធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់ និងរបៀបរៀបរយសង្គម គប្បីត្រូវទទួលការផ្តន្ទាទោសតាមច្បាប់កំណត់។

១១.ឈ្មោះ [redacted] **សុផាន់** ពុំបានតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ប្តឹងទាមទារសំណងខូចខាត និងជម្ងឺចិត្តអ្វីទេ គប្បីតុលាការមិនលើកមកពិចារណាឡើយ។

១២.មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] **រស្មី** ហៅ **ម៉ោល** ឈ្មោះ [redacted] **វ៉ែង** ហៅ **ញ៉ាញ់** និងឈ្មោះ [redacted] **ហ័ង** ពីបទ: **កំហែងយក** ប្រព្រឹត្តនៅចំណុចភូមិស្រែរអូរ ឃុំពាំងល្វា ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២៣ តាមបញ្ញត្តិមាត្រា៣៦៣ និងមាត្រា៣៦៤ នៃក្រមព្រហ្មទណ្ឌ។

១៣.តាមសេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការប្តឹងសុំតម្កល់ការចោទប្រកាន់លើជនជាប់ចោទឈ្មោះ [redacted] **រស្មី** ហៅ **ម៉ោល** ភេទប្រុស អាយុ ១៥ឆ្នាំ ឈ្មោះ [redacted] **វ៉ែង** ហៅ **ញ៉ាញ់** ភេទប្រុស អាយុ ១៨ឆ្នាំ និងឈ្មោះ [redacted] **ហ័ង** ភេទប្រុស អាយុ ២៤ឆ្នាំ ពីបទ: **កំហែងយកមានស្ថានទម្ងន់ទោសដោយប្រើប្រាស់អាវុធ** ប្រព្រឹត្តនៅចំណុចភូមិស្រែរអូរ ឃុំពាំងល្វា ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២៣ តាមបញ្ញត្តិមាត្រា៣៦៣ និងមាត្រា៣៦៦ នៃក្រមព្រហ្មទណ្ឌ។ ឃើញថាមានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ ដូចនេះគប្បីតុលាការលើកយកមកពិចារណា និងសម្រេចតាមផ្លូវច្បាប់។

## ហេតុដូច្នេះសម្រេច

១.ឱ្យជនជាប់ចោទឈ្មោះ [redacted] **រស្មី** ហៅ **ម៉ោល** ភេទប្រុស អាយុ ១៥ឆ្នាំ ជនជាតិខ្មែរ ឈ្មោះ [redacted] **វ៉ែង** ហៅ **ញ៉ាញ់** ភេទប្រុស អាយុ ១៨ឆ្នាំ ជនជាតិខ្មែរ និងឈ្មោះ [redacted] **ហ័ង** ភេទប្រុស អាយុ ២៤ឆ្នាំ ជនជាតិខ្មែរ រួចផុតពីបទ: **កំហែងយកមានស្ថានទម្ងន់ទោសដោយប្រើប្រាស់អាវុធ** ប្រព្រឹត្តនៅចំណុចភូមិស្រែរអូរ ឃុំពាំងល្វា ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២៣ តាមបញ្ញត្តិមាត្រា៣៦៣ និងមាត្រា៣៦៦ នៃក្រមព្រហ្មទណ្ឌ។

២.ជនជាប់ចោទឈ្មោះ [redacted] **រស្មី** ហៅ **ម៉ោល** ភេទប្រុស អាយុ ១៥ឆ្នាំ ជនជាតិខ្មែរ ឈ្មោះ [redacted] **វ៉ែង** ហៅ **ញ៉ាញ់** ភេទប្រុស អាយុ ១៨ឆ្នាំ ជនជាតិខ្មែរ និងឈ្មោះ [redacted] **ហ័ង** ភេទប្រុស អាយុ ២៤ឆ្នាំ ជនជាតិខ្មែរ មានពិរុទ្ធភាព ពីបទ: **កំហែងយក** ប្រព្រឹត្តនៅចំណុចភូមិស្រែរអូរ ឃុំពាំងល្វា ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២៣ តាមបញ្ញត្តិមាត្រា៣៦៣ និងមាត្រា៣៦៤ នៃក្រមព្រហ្មទណ្ឌ។

**៣.ផ្តន្ទាទោស:**

ក.ឈ្មោះ [redacted] **រស្មី** ហៅ **ម៉ោល** ភេទប្រុស អាយុ ១៥ឆ្នាំ (កើតថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០០៧) ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរនៅផ្ទះ ទីកន្លែងកំណើតភូ[redacted] ខេត្តកំពង់ស្ពឺ ទីលំនៅបច្ចុប្បន្ន

ភូមិ[redacted] ខេត្តកំពង់ស្ពឺ ឪពុកឈ្មោះ [redacted] រឿន (ស) ម្ដាយឈ្មោះ [redacted] សុភាព (រ) នៅលីវ ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន។

ដាក់ពន្ធនាគារកំណត់រយៈពេលចំនួន ០២(ពីរ)ឆ្នាំ ០៦(ប្រាំមួយ)ខែ គិតចាប់ពីថ្ងៃឃុំខ្លួន ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២៣។

**ខ.**ឈ្មោះ [redacted] វ៉េង ហៅ ញ៉ាញ់ ភេទប្រុស អាយុ ១៨ឆ្នាំ (កើតថ្ងៃទី១៤ ខែមករា ឆ្នាំ២០០៥) ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរកម្មកររោងចក្រ ទីកន្លែងកំណើតភូមិ[redacted] ខេត្តកំពង់ស្ពឺ ទីលំនៅបច្ចុប្បន្នភូមិ[redacted] ខេត្តកំពង់ស្ពឺ ឪពុកឈ្មោះ[redacted]រី (រ) ម្ដាយឈ្មោះ [redacted] ជ្រឹប (រ) នៅលីវ ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន។

ដាក់ពន្ធនាគារកំណត់រយៈពេលចំនួន ០៤(បួន)ឆ្នាំ គិតចាប់ពីថ្ងៃឃុំខ្លួន ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២៣។

**គ.**ឈ្មោះ [redacted] ហ៊ង ភេទប្រុស អាយុ ២៤ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរជាងម៉ូតូ ទីកន្លែងកំណើតភូ[redacted] ខេត្តកំពង់ស្ពឺ ទីលំនៅបច្ចុប្បន្នភូមិលងទឹក១ ឃុំរុងរឿង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ ឪពុកឈ្មោះ [redacted] ហួរ (រ) ម្ដាយឈ្មោះ [redacted] សុវ៉ាន់ (រ) ប្រពន្ធឈ្មោះ[redacted] ស្រីតូច មានកូនចំនួន ០១នាក់ ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន។

ដាក់ពន្ធនាគារកំណត់រយៈពេល ០៣(បី)ឆ្នាំ គិតចាប់ពីថ្ងៃឃុំខ្លួន ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២៣។

ពីបទ: **កំហែងយក** ប្រព្រឹត្តនៅចំណុចភូមិស្រែអូរ ឃុំពាំងល្វា ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២៣ តាមបញ្ញត្តិមាត្រា៣៦៣ និងមាត្រា៣៦៤ នៃក្រមព្រហ្មទណ្ឌ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី១៩ ខែមករា ឆ្នាំ២០២៤ និងប្រកាសជាសាធារណៈនៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២៤ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted]រស្មី ហៅ ម៉ោល ឈ្មោះ [redacted] វ៉េង ហៅ ញ៉ាញ់ និងឈ្មោះ [redacted] ហ៊ង។

ភាគីមានសិទ្ធិប្ដឹងឧទ្ធរណ៍ក្នុងរយៈពេលដែលច្បាប់កំណត់។

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមប្រឹក្សា** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
|---|---|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |

[redacted]

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃព្រហស្បតិ៍ ១៣កើត ខែមាឃ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

កំពង់ស្ពឺ ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២៤

**ក្រឡាបញ្ជី**

[redacted]

បានឃើញ

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]



Scanned with CamScanner